# បុព្វបទបរាភវសូត្រ

ធម៌បរាភវសូត្រនេះព្រះបរមសាស្តាចារ្យ នៃយើងទាំងឡាយ ទ្រង់បានដោះស្រាយចំពោះពួកទេវតាទាំងឡាយ ដែលមានចម្ងល់អំពីហេតុចម្រើន និងវិនាស ហើយចុះមកទូលសួរព្រះអង្គក្នុងវេលាជិតភ្លឺ ក្នុងកាលដែលទ្រង់គង់ប្រថាប់ព្រះឥរិយាបថនៅវត្តជេត ដែលជាអារាមអនាថបណ្ឌិកបានសាងថ្វាយនោះ ។ ព្រះអង្គទ្រង់បានសម្តែងប្រោសពួកទេវតាទាំងនោះចំនួន ១២ គាថា ។ លុះក្រោយមកព្រះសង្ឃខ្មែរបានយកធម៌នេះមកសូត្រក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ រយៈវេលា ១៥ ថ្ងៃ ជាហេតុបណ្តាលឲ្យអស់លោកខ្លះយល់ច្រឡំថា ធម៌នេះជាធម៌សម្រាប់លោកសង្ឃ គឺលោកសង្ឃសូត្រឲ្យពួកប្រេត ព្រោះគេជឿថាយមបាលបានដោះលែងពួកប្រេតឲ្យទៅរកញាតិសន្តាន ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ ហើយពួកប្រេតទាំងឡាយនោះមកបានតែពេលយប់ ពិសេសគឺពេលទៀបភ្លឺ ។ ការពិតធម៌នេះពុំមែនសម្រាប់នរណាម្នាក់ទេ គឺសម្រាប់មនុស្សទូទៅសូត្រ អាន ឬស្តាប់ និងពិចារណាឲ្យយល់ ហើយយកទៅអនុវត្តតាម ។ បើគ្រាន់តែសូត្រប្រកបដោយបទអន្លង់អន្លោច តែមិនយល់ន័យ ឬយល់ដែរតែមិនអនុវត្តតាម នោះវានឹងមានប្រយោជន៍អ្វីដល់ការសូត្រ ? ឯលោកសង្ឃសូត្រក្នុងពេលជិតភ្លឺនោះមកពីៈ ១. ប្រហែលជាលោកធ្វើតាមព្រះដ៏មានព្រះភាគ កាលទ្រង់ប្រោសទេវតា។

២. វាជាកិច្ចវត្តរបស់លោកសង្ឃ គឺលោកសង្ឃគ្រប់អង្គត្រូវតែសូត្រធម៌ថ្វាយបង្គំព្រះព្រឹកល្ងាច និងធម៌ផ្សេងៗ ទៀត បើខាតកិច្ចវត្តនេះ ការបួសរបស់លោកសង្ឃនោះ ច្បាស់ជាអស់ន័យ ។ ៣. វាមានប្រយោជន៍សម្រាប់កសិករដែរ ពីព្រោះពួកគាត់មិនដែលសម្រាន្តរហូតថ្ងៃរះទេ ម៉ោង ៣-៤ ក្រោកហើយ ។ អ្នកខ្លះ បើទោះជាមិនចូលចិត្តស្តាប់ក៏ដោយ ក៏ត្រូវតែក្រោកដែរ ព្រោះគាត់...ថ្លង់? ។

រឿងប្រេតនេះ ខុសត្រូវយ៉ាងណានោះ ខ្ញុំកូរណាអាត្មាភាព មិនហ៊ានធានាទេ ស្រេចតែអស់លោកអ្នកអានពិចារណាទៅចុះ ព្រោះបើតាមគម្ពីរតិរោកុឌ្ឌសូត្រនោះ ព្រះដ៏មានព្រះភាគទ្រង់បានត្រាស់សម្តែងអំពីប្រេតដែលជាញាតិរបស់ព្រះបាទពិម្ពិសាររមែន ប៉ុន្តែទ្រង់ពុំបានមានបន្ទូលថាៈ ប្រេតទាំងឡាយត្រូវតែបានដោះលែងរាល់រដូវភ្ជុំបិណ្ឌ ដើម្បីឲ្យស្វែងរកញាតិសន្តានរបស់ខ្លួននោះទេ ។ ទោះជាយ៉ាងណាក៏ដោយ ការរក្សាប្រពៃណីទំនៀមទំលាប់ និងវប្បធម៌ជាតិរបស់ខ្លួនជាកាតព្វកិច្ចដ៏ជាចម្បងរបស់បុគ្គលម្នាក់ ៗ តែការរៀននូវទ្រឹស្តីដ៏ល្អរបស់អ្នកប្រាជ្ញទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើម ពុំមែនមានន័យថាយើងធ្វើខុសនោះទេ ។ ឯការសូត្រ ឬអានបរាភវសូត្រ ឬធម៌ដទៃទៀតនោះ អ្នកណាក៏គេអាចធ្វើបានដែរ ឲ្យតែគេមានសទ្ធាជ្រះថ្លា និងមានពេល មិនចាំបាច់អ្នកនោះទាល់តែជាពុទ្ធសាសនិកជននោះទេ ។

# បរាភវសូត្រ

## សូត្រដែលជាហេតុនាំឲ្យវិនាស ១២ យ៉ាង

*១/បុ.* **បរាភវន្តំ បុរិសំ មយំ បុច្ឆាម គោតមំ**

**ភវន្តំ បុដ្ឋុមាគម្ម កឹ បរា ភវតោ មុខំ ។**

*យើងខ្ញុំទាំងឡាយ មកសូមទូលសួរ នូវហេតុដែលគួរ*

*ចម្រើនវិនាស ប្រុសស្រីក្នុងលោក- សន្និវាស*

*ដែលនឹងវិនាស សាបសូន្យចាកគុណ ឆ្ពោះព្រះគោត្តម*

*ព្រះអង្គមានបុណ្យ មេត្តានិមន្តសម្តែងឲ្យទាន ធម្មជាតិដូចម្តេច*

*ដែលជាប្រធាន នាំឲ្យសត្វមាន សេចក្តីវិនាស ។*

*១/វិ.* **សុវិជានោ ភវំ ហោតិ សុវិជានោ បរាភវោ**

**ធម្មកាមោ ភវំ ហោតិ ធម្មទេស្សី បរាភវោ ។**

*អ្នកដែលចម្រើន គេក៏អាចស្គាល់ងាយ អ្នកដែលអន្តរាយ*

*គេក៏អាចស្គាល់ពិត អ្នកប្រាថ្នាធម៌ ល្អិតល្អក្នុងចិត្ត*

*ហើយខំប្រព្រឹត្ត នឹងបានចម្រើន ។ អ្នកដែលទ្រុស្តធម៌*

*ស្អប់ធម៌ឥតកើន ឥតកើនចម្រើន វិនាសទៅមុខ ។*

*២/បុ.* **ឥតិ ហេតំ វិជានាម បឋមោ សោ បរាភវោ**

**ទុតិយោ ភគវា ព្រូហិ កឹ បរា ភវតោ មុខំ ។**

*យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនោះឯង*

*ព្រោះហេតុដូច្នោះ ក្ដីវិនាសនេះ បើរាប់សង្គ្រោះ*
*វិនាសនោះឈ្មោះ ទី ១ ទាន់ហន់ ។ បពិត្រព្រះអង្គ*
*ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្ដែងឲ្យទាន*
*វិនាសទី ២ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្ដីវិនាស ។*

*២/វិ.* **អសន្តស្ស បិយោ ហោន្តិ សន្តេន កុរុតេ បិយំ**
**អសតំ ធម្មំ រោចេតិ តំ បរា ភវតោ មុខំ ។**

*អ្នកដែលស្រឡាញ់ ពេញចិត្តស្នេហា តែនឹងមនុស្សណា*
*អសប្បុរស តែងមិនស្រឡាញ់ ពេញចិត្តទាំងអស់*
*នឹងអ្នកសប្បុរស មកធ្វើជាមិត្រ ។ សេចក្ដីស្រឡាញ់*
*ពេញចិត្តគំនិត ហើយទៅគប់មិត្រ អសប្បុរស*
*គាប់ចិត្តក្នុងធម៌ ឬមួយរបស់ ហេតុនោះទាំងអស់ នាំឲ្យវិនាស ។*

*៣/បុ.* **ឥតិ ហេតំ វិជានាម ទុតិយោ សោ បរាភវោ**
**តតិយំ ភគវា ព្រូហិ កឹ បរា ភវតោ មុខំ ។**

*យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្ដែង វិនាសនោះឯង*
*ព្រោះហេតុដូច្នោះ ក្ដីវិនាសនេះ បើរាប់សង្គ្រោះ*
*វិនាសនោះឈ្មោះ ទី ២ ទាន់ហន់ ។ បពិត្រព្រះអង្គ*
*ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្ដែងឲ្យទាន*
*វិនាសទី ៣ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្ដីវិនាស ។*

៣/វិ. **និទ្ទាសីលី សភាសីលី    អនុដ្ឋាតា ច យោ នរោ**
**អលសោ កោធបញ្ញាណោ    តំ បរា ភវតោ មុខំ ។**

អ្នកដេកច្រើន ១ និយាយច្រើន ១ នឹងអ្នកឥតព្រួយ
ឥតគិតប្រឹងប្រែង អ្នកខ្ជិលច្រអូស មិនមានខ្នះខ្នែង
ខឹងច្រើនសម្ដែង ឲ្យគេឃើញបាន ហេតុធម៌ទាំងនោះ
មិនជាកល្យាណ នាំឲ្យខកខាន ខាតខូចប្រយោជន៍
មានជាប្រធាន តិចច្រើនដោយហោច នាំបង់ប្រយោជន៍
ហើយឲ្យវិនាស ។

៤/បុ. **ឥតិ ហេតំ វិជានាម    តតិយោ សោ បរាភវោ**
**ចតុត្ថំ ភគវា ព្រូហិ    កឹ បរា ភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្ដែង វិនាសនោះឯង
ព្រោះហេតុដូច្នោះ ក្ដីវិនាសនេះ បើរាប់សង្គ្រោះ
វិនាសនោះឈ្មោះ ទី ៣ ទាន់ហន់ ។ បពិត្រព្រះអង្គ
ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្ដែងឲ្យទាន
វិនាសទី ៤ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្ដីវិនាស ។

៤/វិ. **យោ មាតរំ បិតរំ វា    ជិណ្ណកំ គតយោព្វនំ**
**បហុសន្តោ ន ភរតិ    តំ បរា ភវតោ មុខំ ។**

នរជនណា មានទ្រព្យធនធាន ហើយខ្លួនមិនបាន ចិញ្ចឹមរក្សា

*មាតាបិតា ដែលចាស់ជរា ហេតុនោះទៅជា នាំឲ្យវិនាស ។*

*៥/បុ.* **ឥតិ ហេតំ វិជានាម ចតុត្ថោ សោ បរាភវោ**
**បញ្ចមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

*យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនោះឯង*
*ព្រោះហេតុដូច្នោះ ក្តីវិនាសនេះ បើរាប់សង្គ្រោះ*
*វិនាសនោះឈ្មោះ ទី ៤ ទាន់ហាន់ ។ បពិត្រព្រះអង្គ*
*ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឲ្យទាន*
*វិនាសទី ៥ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្តីវិនាស ។*

*៥/វិ.* **យោ ព្រាហ្មណំ សមណំ វា អញ្ញំ វាបិ វនិព្វកំ**
**មុសាវាទេន វញ្ចេតិ តំ បរាភវតោ មុខំ ។**

*ជនបញ្ឆោតព្រាហ្មណ៍ ឬមួយសមណៈ ពួកស្មូម ឬអ្នក ដទៃ ៗ*
*ដោយមុសាវាទឃ្លាតពាក្យប្រពៃ នោះប្រធាននៃសេចក្តីវិនាស។*

*៦/បុ.* **ឥតិ ហេតំ វិជានាម បញ្ចមោ សោ បរាភវោ**
**ឆដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

*យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនោះឯង*
*ព្រោះហេតុដូច្នោះ ក្តីវិនាសនេះ បើរាប់សង្គ្រោះ*
*វិនាសនោះឈ្មោះ ទី ៥ ទាន់ហាន់ ។ បពិត្រព្រះអង្គ*
*ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឲ្យទាន*

*វិនាសទី ៦ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្តីវិនាស ។*

*៦/វិ.* **បហូតវិត្តោ បុរិសោ សហិរញ្ញោ សភោជនោ**
**ឯកោ ភុញ្ជតិ សាទូនិ តំ បរាភវតោ មុខំ ។**

*ពួកជនអ្នកមាន ទ្រព្យធនធានច្រើន មាសប្រាក់ចម្រើន*
*នឹងគ្រឿងអាហារ លបលាក់របស់ ដែលឆ្ងាញ់ពិសា*
*ស៊ីម្នាក់ឯងណា ប្រធានវិនាស ។*

*៧/បុ.* **ឥតិ ហេតំ វិជានាម សត្តមោ សោ បរាភវោ**
**អដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។**

*យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនោះឯង*
*ព្រោះហេតុដូច្នោះ ក្តីវិនាសនេះ បើរាប់សង្គ្រោះ*
*វិនាសនោះឈ្មោះ ទី ៦ ទាន់ហន់ ។ បពិត្រព្រះអង្គ*
*ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឲ្យទាន*
*វិនាសទី ៧ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្តីវិនាស ។*

*៧/វិ.* **ជាតិត្ថទ្ធោ ធនត្ថទ្ធោ គោត្តត្ថទ្ធោ ច យោ នរោ**
**សញ្ញាតឹ អតិមញ្ញេតិ តំ បរាភវតោ មុខំ ។**

*អ្នកដែលប្រកាន់ ជាតិទ្រព្យត្រកូល ហើយមិនប្រមូល*
*សាច់ញាតិសន្តាន មើលងាយញាតិខ្លួន ដោយអាងខ្លួនមាន*
*នោះជាប្រធាន សេចក្តីវិនាស ។*

៨/បុ. ឥតិ ហេតំ វិជានាម សត្តមោ សោ បរាភវោ
អដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនោះឯង
ព្រោះហេតុដូច្នោះ ក្តីវិនាសនេះ បើរាប់សង្គ្រោះ
វិនាសនោះឈ្មោះ ទី ៧ ទាន់ហាន់ ។ បពិត្រព្រះអង្គ
ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឲ្យទាន
វិនាសទី ៨ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្តីវិនាស ។

៨/វិ. ឥត្ថីធុត្តោ សុរាធុត្តោ អក្ខធុត្តោ ច យោ នរោ
លទ្ធំ លទ្ធំ វិនាសេតិ តំ បរាភវតោ មុខំ ។

ជនអ្នកប្រព្រឹត្ត ល្បែងបីប្រការ ល្បែងស្រីល្បែងស្រា
ល្បែងភ្នាល់ទាំងឡាយ ធ្វើទ្រព្យខ្លួនមាន ឲ្យអន្តរាយ
ការល្បែងទាំងឡាយ នោះនាំឲ្យវិនាស ។

៩/បុ. ឥតិ ហេតំ វិជានាម អដ្ឋមោ សោ បរាភវោ
នវមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនោះឯង
ព្រោះហេតុដូច្នោះ ក្តីវិនាសនេះ បើរាប់សង្គ្រោះ
វិនាសនោះឈ្មោះ ទី ៨ ទាន់ហាន់ ។ បពិត្រព្រះអង្គ
ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឲ្យទាន

វិនាសទី ៩ អ្វីជាប្រធាន  នាំសត្វឲ្យមាន  សេចក្តីវិនាស ។

៩/វិ. **សេហិ ទារេហិ អសន្តុដ្ឋោ  វេសិយាសុ បទុស្សតិ**
**ទុស្សតិ បរទារេសុ  តំ បរាភវតោ មុខំ ។**

ប្រុសមិនត្រេកអរ  នឹងប្រពន្ធខ្លួន  ហើយទៅជាប់ជួន
នឹងស្រីពេស្យា  ទ្រុស្តនឹងប្រពន្ធ  កូនជននានា
ហេតុនោះទៅជា  នាំឲ្យវិនាស ។

១០/បុ. **ឥតិ ហេតំ វិជានាម  នវមោ សោ បរាភវោ**
**ទសមំ ភគវា ព្រូហិ  កឹ បរាភវតោ មុខំ ។**

យើងខ្ញុំទាំងឡាយ  បានដឹងជាក់ស្តែង  វិនាសនោះឯង
ព្រោះហេតុដូច្នោះ  ក្តីវិនាសនេះ  បើរាប់សង្គ្រោះ
វិនាសនោះឈ្មោះ  ទី ៩ ទាន់ហាន់ ។  បពិត្រព្រះអង្គ
ព្រះនាមភគវន្ត  សូមទ្រង់និមន្ត  សម្តែងឲ្យទាន
វិនាសទី ១០ អ្វីជាប្រធាន  នាំសត្វឲ្យមាន  សេចក្តីវិនាស ។

១០/វិ. **អតីតយោព្វនោ បោសោ  អានេតិ តិម្ពរុត្ថនឹ**
**តស្សា ឥស្សា ន សុបតិ  តំ បរាភវតោ មុខំ ។**

បុរសមានវ័យ  ដែលចាស់ហួសពេក  ហើយមានតម្រេក
ដោយក្តីតណ្ហា  នាំយកស្រីក្មេង  មកធ្វើភរិយា
ហេតុនោះទៅជា  នាំឲ្យវិនាស ។

១១/បុ. ឥតិ ហេតំ វិជានាម ទសមោ សោ បរាភវោ
ឯកាទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

*យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្ដែង វិនាសនោះឯង*
*ព្រោះហេតុដូច្នោះ ក្ដីវិនាសនេះ បើរាប់សង្គ្រោះ*
*វិនាសនោះឈ្មោះ ទី ១០ ទាន់ហាន់ ។ បពិត្រព្រះអង្គ*
*ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្ដែងឲ្យទាន*
*វិនាសទី ១១ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្ដីវិនាស ។*

១១/វិ. ឥត្ថី សោណ្ឌី វិកិរណី បុរិសំ វាបិ តាទិសំ
ឥស្សរិ យស្មឹ ឋបេតិ តំ បរា ភវតោ មុខំ ។

*បុរសតាំងស្រី អ្នកលេងខ្ជះខ្ជាយ ឬស្រីទាំងឡាយ*
*តាំងបុរសនោះ ដែលជាអ្នកលេង ខ្ជះខ្ជាយដូច្នោះ*
*អំពើទាំងនោះ នាំឲ្យវិនាស ។*

១២/បុ. ឥតិ ហេតំ វិជានាម ឯកាទសមោ សោ បរាភវោ
ទ្វាទសមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

*យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្ដែង វិនាសនោះឯង*
*ព្រោះហេតុដូច្នោះ ក្ដីវិនាសនេះ បើរាប់សង្គ្រោះ*
*វិនាសនោះឈ្មោះ ទី ១១ ទាន់ហាន់ ។ បពិត្រព្រះអង្គ*
*ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្ដែងឲ្យទាន*

*វិនាសទី ១២ អ្វីជាប្រធាន នាំសត្វឲ្យមាន សេចក្តីវិនាស ។*

*១២/វិ.* **អប្បភោគោ មហាតណ្ហោ ខត្តិយេ ជាយតេ កុលេ**

**សោ ច រជ្ជំ បត្ថយតិ តំ បរា ភវតោ មុខំ ។**

*ជនណាកើតក្នុង ត្រកូលជាក្សត្រ អ្នកខ្សត់សម្បត្តិ*

*ហើយប្រាថ្នាធំ ចង់ធ្វើជាស្តេច សោយរាជ្យស្តុកស្តម្ភ*

*ហេតុនោះនឹងនាំ ឲ្យដល់វិនាស ។*

**ឯតេ បរា ភវេ លោកេ បណ្ឌិតោ ស មវេក្ខិយេ**

**អរិ យទស្សនសម្បន្នោ ស លោកំ ភជតេ សិវំ ។**

*ជនជាបណ្ឌិត គំនិតប្រសើរ បានឃើញដំណើរ*

*នៃហេតុវិនាស ដល់សត្វលោ- ក:សន្និវាស*

*គេចពីវិនាស គប់រកចម្រើន ។*

